ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៥ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I.ទីស្ដីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១១-៧-១៩៩៥ – អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្ដីពីការបង្កើតក្រុមប្រឹក្សាស្ដារ អភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ១០៩៤

១១-៧-១៩៩៥ – អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្ដីពីការផ្ទេរមេឃុំបារាំងសេស ១០៩៧

១២-៧-១៩៩៥ – អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្ដីពីការផ្ទេរមន្ត្រីរាជការ ១០៩៨

១៥-៧-១៩៩៥ – អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ចនាយម... ១០៩៩

២-សេចក្ដីសំរេច

១០-៧-១៩៩៥ – សេចក្ដីសំរេចលេខ ៤៨ សសរ ស្ដីពីការបង្កើតលេខាធិការដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១១០០

II-ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សេចក្ដីសំរេច

១០-៧-១៩៩៥ – សេចក្ដីលេខ ០៨៨ សហវ.ប ស្ដីពីការបង្កើតគណៈកម្មការ ប្រលងបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាហិរញ្ញវត្ថុគណនេយ្យ ជំនាន់ទី ៩ ១១០៣

១២-៧-១៩៩៥ – សេចក្ដីសំរេចលេខ ០៩០ សហវ.ប ស្ដីពីការបង្កើតគណៈកម្មការ កណ្ដាលតម្លើងកាំបៀវត្ស ជូនមន្ត្រីរាជការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ១៩៩៥ ១១០៥

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៣-៧-១៩៩៥ – ប្រកាសលេខ ៤៩៦ ផក.ប្រក អនុញ្ញាតអោយលោក **ស៊ឹន្ទ គីលីម** ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម ១១០៧

១៣-៧-១៩៩៥ – ប្រកាសលេខ ៤៩៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **តាំង គាន** ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១១០៧

១៣-៧-១៩៩៥ – ប្រកាសលេខ ៥០០ ផក.ប្រក អនុញ្ញាតអោយលោក **ឌ៉ា ម៉ុនថៃ** ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១១០៨

១៣-៧-១៩៩៥ – ប្រកាសលេខ ៥០១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ជុំ អៀមហួយ** ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១១០៨

១៣-៧-១៩៩៥ – ប្រកាសលេខ ៥០២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **អ៊ុំ សុវណ្ណនី** ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ ១១០៩

១៣-៧-១៩៩៥ – ប្រកាសលេខ ៥០៣ ផក.ប្រក អនុ[illegible] **ហាក់ ម៉ៅ** ជនជាតិខ្មែរ បើកដំណើរ[illegible]ម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១១០៩

១៣-៧-១៩៩៥ – ប្រកាសលេខ ៥០៤ ផក.ប្រក អនុញ្ញាតអោយលោក **ហួត ចាន់ថូ** ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម ១១១០

១៣–៧–១៩៩៥ – ប្រកាសលេខ ៥០៥ ផក.ប្រក អនុញ្ញាតអោយលោក ចៅ ខេងឡុង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិន ស្រូវ កំលាំង ១៨ សេះ [illegible]

១៣–៧–១៩៩៥ – ប្រកាសលេខ ៥០៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ហ៊េក សុផល ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកគ្រាប់ ១១១១

១៣–៧–១៩៩៥ – ប្រកាសលេខ ៥០៧ ផក.ប្រក អនុញ្ញាតអោយលោក ដុំ ជីនអាន ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម ១១១១

១៣–៧–១៩៩៥ – ប្រកាសលេខ ៥០៨ ផក.ប្រក អនុញ្ញាតអោយលោក អ៊ិត ហុងស្រី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១១១២

១៣–៧–១៩៩៥ – ប្រកាសលេខ ៥០៩ ផក.ប្រក អនុញ្ញាតអោយលោក ហាក់ ស៊ីសែ ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកស៊ីវ យីហោ «ខ្លាឃ្មុំ» ១១១២

១៣–៧–១៩៩៥ – ប្រកាសលេខ ៥១០ ផក.ប្រក អនុញ្ញាតអោយលោក ឡុង ហេង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១១១៣

១៣–៧–១៩៩៥ – ប្រកាសលេខ ៥១១ ផក.ប្រក អនុញ្ញាតអោយលោក អ៊ាំង ពីម ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតសាប៊ូ ១១១៣

១៣–៧–១៩៩៥ – ប្រកាសលេខ ៥១២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អ៊ុច សារី ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មផលិត

ម្សៅអង្ករ និង ម្សៅធាយឺហោ «ផា. ផា» ១១១៤

១៣-៧-១៩៩៥ - ប្រកាសលេខ ៥១៣ ផក.ប្រក អនុញ្ញាតអោយលោក **សុខ ញ៉ូ** ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកក ដើម និង ទឹកកកគ្រាប់ ១១១៤

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១២-៧-១៩៩៥ - ប្រកាសលេខ ១៤៧/៩៥ ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ ១១១៥

១៥-៧-១៩៩៥ - ប្រកាសលេខ ១៤៨/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយសារពត៌មាន «តាសោម» ដំណើរការឡើងវិញ និង ប្តូរឈ្មោះមកជាសារពត៌មាន «សាធារណរដ្ឋ» វិញ ១១១៦

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

១៣-៧-១៩៩៥ - ប្រកាសលេខ ១២៥ ប្រក.វវស.ប ស្តីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង ១១១៧

១៣-៧-១៩៩៥ - ប្រកាសលេខ ១២៦ ប្រក.វវស.ប ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ១១១៨

១៤-៧-១៩៩៥ - ប្រកាសលេខ ១២៩ ប្រក.វវស.ប ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ១១១៩

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

១៣-៧-១៩៩៥ - ប្រកាសលេខ ៥៤៩ សក.ដជ.តពយ ស្តីពីយានយន្តដែល

ខូចប្រើការលែងកើត ១១២០

១៥-៧-១៩៩៥ – ប្រកាសលេខ ៥៥១ ប្រក.សក.ហរ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ ការដ្ឋានសាងសង់ព្រលានយន្តហោះពោធិចិនតុង ១១២២

៦-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

១២-៧-១៩៩៥ – ប្រកាសលេខ ១៤៤/៩៥ កធស.ប្រក ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និង សាសនា ១១២៤

៧-ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

១៣-៧-១៩៩៥ – ប្រកាសលេខ ១២៥៥ ប្រក.បស្ត ស្តីពីការទទួលស្គាល់ និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ១១២៥

១៣-៧-១៩៩៥ – ប្រកាសលេខ ១២៥៦ ប្រក.បស្ត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១២៦

I .ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៦ អនក្រ.បក

ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារ
អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលមានសមាសភាពដូចតទៅ ៖

១-សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

២–សម្តេចនាយករដ្ឋមន្ត្រីទី ២ សហប្រធាន

៣–ឯកឧត្តម តាវ សេងហួរ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អនុប្រធាន

៤–ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ និតិសម្បទា និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥–ឯកឧត្តម ចេង ម៉េងលាង អគ្គលេខាធិការ...ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៦–ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

៧–ឯកឧត្តម ជា ចាន់តូ រដ្ឋមន្ត្រីក្រសួងផែនការ សមាជិក

៨–ឯកឧត្តម ហុង ស៊ុនហួត រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៩–ឯកឧត្តម នុទ កានុន រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០–ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១១–លោក ជុំ ប៊ុនរ៉ុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១២–លោក លឹម គានហោ ប្រធាននាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ សមាជិក

១៣–លោក សារ៉ាត់ ខាន់ អគ្គនាយក នាយកខុទ្ទកាល័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការ

មាត្រា ២ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីអនុវត្តអោយស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង មានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសំរេចអំពីមធ្យោបាយ សម្ភារៈ ទុន និង ការងារផ្សេង ។ ទៀត ដែលជួយអោយសំរេចរាល់ភារកិច្ចដែលមានចែងក្នុងមាត្រា ៣ ។

មាត្រា ៣ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចដូចខាងក្រោម ÷

- ទទួលបន្ទុកចាត់ចែងអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង កម្មវិធីជាតិនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា លើកិច្ចការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទំលាប់ធ្វើដើម្បីផ្គត់ផ្គង់ខ្លួនឯង អោយទៅជាការផលិតដើម្បីនាំចេញ ព្រមទាំងបន្ថយជាជំហាន ៗ នូវគម្លាតឆ្ងាយរវាងជនបទ និង ទីក្រុង ។
- កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើអោយការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។
- កំណត់អាទិភាព នៃតម្រូវការក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ទៅតាមកម្មវិធី និង តាមសភាពការណ៍ជាក់ស្តែង ។
- ចលនា និង សំរបសំរួលរវាងគ្រប់សមាសភាពសេដ្ឋកិច្ច ជាពិសេសក្រុមហ៊ុនឯកជន ជាមួយក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដើម្បីបង្កនូវភាពងាយស្រួល និង ភាពសហការគ្នាល្អក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។
- ពិនិត្យ និងសំរេចលើរាល់សេចក្តីស្នើសុំស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងផ្តល់យោបល់ណែនាំដល់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ។ រាយការណ៍ និង សុំយោបល់រាជរដ្ឋាភិបាលលើបញ្ហាសំខាន់ ៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៤ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចបង្កើតលេខាធិការដ្ឋានមួយ ដើម្បីជួយការងារ ។

មាត្រា ៥ : សមាជិកក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៦ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

មាត្រា ៧ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សំរាប់ដំណើរការជាក់ស្តែង ។

មាត្រា ៨ : អនុក្រឹត្យលេខ ៧១ អនក្រ. ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង សម្តេច ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ ព្រមទាំងបណ្តាក្រសួង - ស្ថាប័ន និង ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ ចំពោះលោក ALBERT YEUNG ប្រធានក្រុមហ៊ុន Emperor Group ដែលបានឧបត្ថម្ភថវិកាចំនួន ១០០.០០០ដុល្លារ អាមេរិក សំរាប់ជួយដល់វិស័យអភិវឌ្ឍន៍ជនបទ និង កសិកម្ម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨២ អនក្រ.តត

ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ផ្ទេរលោក **ឡិ កុសល** អោយមកបំពេញភារកិច្ចថ្មីក្នុងប្រទេសវិញ នឹងត្រូវបានតែងតាំងជាទីប្រឹក្សាឯកឧត្តម **អ៊ុង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការ

ការអន្តរជាតិ ។

មាត្រា ២ : តែងតាំងលោកជំទាវ **សរ សោរ័ត្ន** ជាអគ្គទីប្រឹក្សា នៃបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំ UNESCO ជំនួសលោក **ឡិ គុសល** ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លោក **ឡិ គុសល** និង លោកជំទាវ **សរ សោរ័ត្ន** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៣ អនក្រ.តត

ស្តីពីការផ្ទេរភារកិច្ច នាយទាហាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចចំពោះលោកវរសេនីយ៍ឯក **ចាយ គីមម៉ុង** នាយរងខុទ្ទកាល័យ អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ បច្ចុប្បន្នត្រូវបានទៅបំរើការងារជាមួយ ឯកឧត្តមឧត្តមសេនីយ៍ទោ **ឌុំ សម្បូរ** ជាទីប្រឹក្សាសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការយោធា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសម្រេចលេខ ៤៨ សសរ

ស្តីពីការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ
នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

* * *

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : បង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាស្ថាប័នមួយដោយឡែក ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងមានទីតាំងអចិន្ត្រៃយ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : សមាសភាពលេខាធិការដ្ឋានមានដូចខាងក្រោម ÷

១-ឯកឧត្តម **ញឹម វណ្ណដា**	បេសកជនពិសេសរបស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២	លេខាអចិន្ត្រៃយ៍
២-ឯកឧត្តមវេជ្ជបណ្ឌិត **ហុង ស៊ុនហួត**	រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង ជាអនុប្រធានកាកបាទក្រហមកម្ពុជា	អនុលេខាអចិន្ត្រៃយ៍
៣-ឯកឧត្តម **នុត ភានុន**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុលេខាអចិន្ត្រៃយ៍
៤-លោកតំណាងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ		សមាជិក
៥-លោកតំណាងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ		សមាជិក
៦-លោកតំណាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ		សមាជិក
៧-លោកតំណាងរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន		សមាជិក
៨-លោកតំណាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ		សមាជិក

៩–លោកតំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
១០–លោកតំណាងរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន សមាជិក
១១–លោកតំណាងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ សមាជិក

ប្រការ ៣ : លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចបានចែងនៅក្នុងមាត្រា ៥ និង មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៧–៣–១៩៩៥ ស្តីពីការបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយសង្កត់ធ្ងន់លើភារកិច្ចដូចខាងក្រោម ÷

– ទប់ស្កាត់ បន្ថយគ្រោះមហន្តរាយ
– ចាត់ចែងការងារពេលមានគ្រោះមហន្តរាយ
– ផែនការស្តារក្រោយពេលគ្រោះមហន្តរាយ និង សំរបសំរួលការងារសិក្សា

ប្រការ ៤ : បណ្តាសមាជិកតំណាងក្រសួង ស្ថាប័ននានា ត្រូវទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ច និង មុខងារដែលបានកំណត់ក្នុងប្រការ ៣ ខាងលើ និង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់លេខាធិការដ្ឋាន ។

ប្រការ ៥ : លេខាធិការដ្ឋាននេះ មានសិទ្ធិជ្រើសរើសបន្ថែមមន្ត្រីរាជការពីក្រសួង ស្ថាប័ននានាតាមទំហំការងារ ដើម្បីបង្កើតផ្នែកទទួលខុសត្រូវការងារដែលបានចែងក្នុងមាត្រា ៥ និង មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៧–៣–១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

លេខាធិការដ្ឋាននេះ ប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីជាផ្លូវការ ។

ប្រការ ៦ : រាល់ការចំណាយ និងមធ្យោបាយបំរើការងាររបស់លេខាធិការដ្ឋាន ស្ថិតនៅក្នុងបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ចំពោះប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេង ៗ របស់សមាជិកនេះ ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាប្រាក់ឧបត្ថម្ភដដែល ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រធានកាកបាទក្រហមកម្ពុជា បណ្តា

ក្រសួងពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ២ ត្រូវទទួលអនុវត្តសេចក្ដីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
សហប្រធានគណៈកម្មាធិការ	សហប្រធានគណៈកម្មាធិការ
ជាតិគ្រប់គ្រងគ្រោះមហន្តរាយ	ជាតិគ្រប់គ្រងគ្រោះមហន្តរាយ
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II .ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្ដីសំរេច លេខ ០៨៨ សសរ.ម

ស្ដីពីការបង្កើតគណៈកម្មការប្រលងបញ្ចប់ការសិក្សា

ថ្នាក់មធ្យមសិក្សាហិរញ្ញវត្ថុគណនេយ្យ ជំនាន់ទី៩

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ នសរកត ១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- យោងការងារចាំបាច់ នៃការប្រលងបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាហិរញ្ញវត្ថុគណនេយ្យ ជំនាន់ទី៩
- តាមសំណើរបស់នាយកដ្ឋានបុគ្គលិក .

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការប្រលងបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាហិរញ្ញវត្ថុ គណនេយ្យ ជំនាន់ទី ៩ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម	**ខាង ម៉េងឈាង**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ជាប្រធាន
២-លោក	**ខង្សុ វ៉ៃដាឆុតរ**	នាយកសាលាមធ្យមសិក្សាហិរញ្ញវត្ថុ	ជាអនុប្រធាន
៣-លោក	**មោក សុធារិន**	ប្រធាននាយកដ្ឋានបុគ្គលិក	ជាអនុប្រធាន
៤-លោក	**ង៉ាំ សុខ**	នាយករងសាលាមធ្យមសិក្សាហិរញ្ញវត្ថុ	ជាសមាជិក
៥-លោក	**ម៉ិច សារឡឿន**	អនុប្រធានការិយាល័យសិក្សា	ជាសមាជិកអចិន្ត្រៃយ៍
៦-លោក	**ឌេត សារឿន**	ប្រធានការិយាល័យសិក្សា	ជាសមាជិក
៧-លោក	**ឌេត សារី**	ប្រធានការិយាល័យរដ្ឋបាល	ជាសមាជិក

ប្រការ ២ : សមាសភាពគណៈកម្មការខាងលើ មានភារកិច្ចរៀបចំចាត់ចែងជាក្រុមសាស្ត្រាចារ្យសំរាប់ប្រលងបញ្ចប់ការសិក្សាលើ២មុខវិជ្ជា :

១-គណនេយ្យទូទៅ	មាន ២ នាក់
២-ថវិការដ្ឋ	មាន ២ នាក់ .

ប្រការ ៣ : រយៈពេលប្រលងបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាហិរញ្ញវត្ថុគណនេយ្យ ត្រូវបានកំណត់ដូចខាងក្រោម :

១-មុខវិជ្ជាគណនេយ្យទូទៅ	ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១៦-៧-៩៥
២-មុខវិជ្ជាថវិការដ្ឋ	ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២៤-៧-៩៥

ប្រការ ៤ : ឯកឧត្តម នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក នាយកសាលាមធ្យមសិក្សាហិរញ្ញវត្ថុ និងអស់លោក ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវ

មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ០៩០ សហវ.ច

ស្តីពីការបង្កើតគណៈកម្មការកណ្តាលតម្លើង

ការបៀវត្សជូនមន្ត្រី រាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រចាំឆ្នាំ ១៩៩៥

* * *

រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ [illegible]
- បានឃើញ [illegible] ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចុះថ្ងៃ [illegible] ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល [illegible]
- បានឃើញព្រះរាជក្រឹត្យ នស.រក[illegible].១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ ៨៩ សសរ ចុះថ្ងៃទី ១០-១០-៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រព័ន្ធបៀវត្ស បុគ្គលិក កម្មកររដ្ឋ
- បានឃើញលិខិតលេខ ១១២-៩៣ មសណ ចុះថ្ងៃទី ០៧-៩-៩៣ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- **បានឃើញការចាំបាច់របស់ក្រសួង ។**

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការកណ្តាលតម្លើងកាំប្រៀវត្ស ប្រចាំឆ្នាំ ១៩៩៥ ជូនមន្ត្រី–រាជការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម	**ឆាយ ថន**	អនុរដ្ឋលេខាធិការ	ជាប្រធាន
២–លោក	**មោក សុធារិន**	ប្រធាននាយកដ្ឋានបុគ្គលិក	ជាអនុប្រធាន
៣–លោកស្រី	**ខ្លូត ឧទផ្កា**	អនុប្រធាននាយកដ្ឋានបុគ្គលិក	សមាជិកអចិន្ត្រៃយ៍
៤–លោក	**ស៊ិន ចន្ទ្រី**	ប្រធានការិយាល័យបៀវត្សពលកម្ម	ជាសមាជិក
៥–លោក	**ឡូច ហៃ**	ប្រធានការិយាល័យបុគ្គលិក	ជាសមាជិក
៦–លោក	**គៀង សត្ថាវុធ**	អនុប្រធានការិយាល័យត្រួតពិនិត្យ	ជាសមាជិក
៧–លោក	**ឆាយ វុធ**	អនុប្រធាន មន្ទីរ	ជាសមាជិក
៨–លោក	**ម៉ែន សេស**	អនុប្រធាននាយកដ្ឋានថវិការដ្ឋ	សមាជិក
៩–លោក	**ម៉ម ប៊ុន**	អនុប្រធាននាយកដ្ឋានហិរញ្ញកិ..	..សមាជិក
១០–លោក	**សាន ផាន់នី**	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស	ជាសមាជិក
១១–លោក	**ម៉ែន ឃួន**	អនុប្រធាននាយកដ្ឋានរបបគណនេយ្យ	ជាសមាជិក
១២–លោក	**ម៉ម និច**	គណកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ	ជាសមាជិក
១៣–លោក	**ហាំង ឈាងច័ណ្ឌ**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងទុនវិនិយោគ	ជាសមាជិក
១៤–លោក	**ចាន់ ស៊ុំ**	អនុប្រធាននាយកដ្ឋានពន្ធដារ	ជាសមាជិក
១៥–លោក	**ពេជ្យ វឌ្ឍ**	អនុប្រធានទីចាត់ការគយ–រដ្ឋាករ	ជាសមាជិក
១៦–លោក	**ហ៊ីម សុវណ្ណ**	អនុប្រធានធនាគារជាតិ	ជាសមាជិក
១៧–លោកស្រី	**តិន ណារ៉េត**	ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា	ជាសមាជិក
១៨–លោក	**វឌ្ឍ វ៉ិដាវុឌ្ឍ**	សាលាមធ្យមសិក្សាហិរញ្ញវត្ថុ	ជាសមាជិក

ប្រការ ២ : សមាសភាពនៃគណៈកម្មការទាំងអស់ខាងលើ មានភារកិច្ចពិនិត្យ ពិភាក្សាលក្ខណៈសម្បត្តិមន្ត្រីរាជការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីគ្រប់អង្គភាពដែលត្រូវតម្លើងកាំ ឬ កែសំរួល កាំប្រាក់បៀវត្ស ។

ប្រការ ៣ : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានបុគ្គលិក និង សាមីជន ត្រូវអនុវត្តតាមសេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ចប់ភារកិច្ច ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

គាត ឈន់

* * *

២-ឯកសាររដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤៩៦ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុន គីលីម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៥៦៦៤ ក.ណ ចុះថ្ងៃទី ០៤-១១-៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្នុង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បើកដំណើរការផលិតកម្មទឹកកកដើម ក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៩៩ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉ាំង គាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០៣៩៩ ក.ធ ចុះថ្ងៃទី ២៤-១១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ

ចំការតាម៉ៅ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **តាំង គាន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិច ៦៥ភាគរយ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០០ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ទ៉ា ម៉ុនថៃ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៩១៩៨៤២ ក.ណ ចុះថ្ងៃទី ២៤–១១–៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្វាយអំពារ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិត្បែងខ្ពស់ ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : លោក **ទ៉ា ម៉ុនថៃ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០១ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ង៉ូ សៀមហ្វាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៣៦៦៥ ក.ណ ចុះថ្ងៃទី ២៥–៨–៨៨ អាស័យដ្ឋានបច្ចុប្បន្ន

ភូមិក្រសាំង ឃុំជើងកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ជូ សៀមហួយ** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០២ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានអ្នកស្រី **អ៊ុំ សុវណ្ណនី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០៣៩៣៦ ត.ក ចុះថ្ងៃទី ១៧-១២-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្នោ សង្កាត់រកាក្នុង ទីរួមខេត្តតាកែវ ខេត្តតាកែវ បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីន កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **អ៊ុំ សុវណ្ណនី** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥០៣ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ចាក់ ម៉ៅ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៨១៥១ ព.ស ចុះថ្ងៃទី ០៦-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៥

ភូមិវត្តជ្រៃ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិសាត់ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ក្រុមទី ៥ ភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិសាត់ ។

ប្រការ ២ : លោក **ឃាត់ ម៉ៅ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៤ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូចផលិតទឹកកកដើម ដែលមានលោក **ឃួត ចាន់ថុ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤២១១៤២ ភ.ព ចុះថ្ងៃទី ០១–៦–៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤២អឺ០ ផ្លូវលេខ ១៧៨ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មនៅក្នុងទីតាំងក្រុមទី ១៤ ភូមិសំរោង សង្កាត់លេខ ១ ទីរួមខេត្តកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៥ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ៅ ឈឿន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៦២១៥ ក.ណ ចុះថ្ងៃទី ២២–៩–៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិគោកត្រប់ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ង៉ោ ឈៀង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៦ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូចផលិតទឹកកកគ្រាប់ដែលមានអ្នកស្រី **យ៉ោក សុផល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០០៤៣២ ត.ក ចុះថ្ងៃទី ២៥-១០-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិចក៏ សង្កាត់រកាក្នុង ទីរួមខេត្តតាកែវ ខេត្តតាកែវ បើកដំណើរការផលិតកម្ម នៅក្នុងទីតាំង ភូមិត្រពាំងអង្គ សង្កាត់រកា ក្រៅ ទីរួមខេត្តតាកែវ ខេត្តតាកែវ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៧ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូចផលិតទឹកកកដើម ដែលមានលោក **ឆ្វ ខឹមអាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥១១៤១ ក.ឆ ចុះថ្ងៃ ទី ២៩-៩-៩៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិឆ្នុកទ្រូ ឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង បើកដំណើរការផលិតកម្មនៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៨ ផក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ិត ហុងស្រី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៣២៨៩ ក.ណ ចុះថ្ងៃទី ២៤-៥-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ៥ ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិព្រៃស្វាយ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ។

ប្រការ ២ : លោក **អ៊ិត ហុងស្រី** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ មុនកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៩ ផក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ហាក់ ស៊ីសែ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៥២១៥ ភ.ព ចុះថ្ងៃទី ០១-៤-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៤ អឺ០ ផ្លូវលេខ ១៣០ ក្រុមទី ២៩ សង្កាត់ផ្សារថ្មីទី ១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្ម ផលិតទឹកស៊ីអ៊ីវយីហោ «ខ្លាឃ្មុំ» នៅក្នុងទីតាំងផ្ទះលេខ ១១ ផ្លូវ លេខ ៣៣៥ ក្រុមទី ១៧ សង្កាត់បឹងកក់ទី ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ហាក់ ស៊ីសែ** ត្រូវរៀបចំរោងសិប្បកម្មរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេលបីខែ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។ ក្នុងពេលចាប់ផ្តើមដំណើរការជាដំបូង ម្ចាស់

សិប្បកម្ម ត្រូវជូនដំណឹងមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ ។

ប្រការ ៣ : លោក **ចាន់ ស៊ីសែ** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកស៊ីអ៊ីវចំនួនពីរមុខ គឺទឹកស៊ីអ៊ីវសញ្ញា «ខ្លាឃ្មុំ» និង សញ្ញា «រូបមាន់» ស្របតាមគំរូ និង ផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សិប្បកម្ម ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតកម្មគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥១០ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឡុង ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៥៦៨២ ក.ធ ចុះថ្ងៃទី ២២-០២-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៧ ភូមិវត្ត ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡុង ហេង** ត្រូវចាប់ផ្តើម ដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥១១ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង ពីង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៣៥២៨ ភ.ព ចុះថ្ងៃទី ០៣-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវលេខ

៣៦៩ ភូមិកណ្តាល សង្កាត់ច្បារអំពៅទី ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតសាប៊ូ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **តាំង ពីទ** ត្រូវបានអនុញ្ញាតអោយផលិត នូវមុខផលិតផលសាប៊ូចំនួនពីរមុខ គឺសាប៊ូដុំសញ្ញា «ក្រាបស» និង សញ្ញា «ផែនដី» ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណាងឡើយ ។

* * *

ប្រកាសលេខ ៥១២ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ុច សារី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៥៣៤៩ ភ.ព ចុះថ្ងៃទី ០៨-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៨៦ ស្ទួន ក្រុមទី ១៧ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតម្សៅអង្ករ និង ម្សៅឆា យីហោ «ដា.ដា» នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **អ៊ុច សារី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលម្សៅអង្ករសញ្ញា «រូបពពែ» និង ម្សៅឆាសញ្ញា «រូបអាប៉ូឡូ» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណាងឡើយ ។

* * *

ប្រកាសលេខ ៥១៣ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ញៀ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណ

ប័ណ្ណលេខ ២៤៧០៧៤ ភ.ព ចុះថ្ងៃទី ២៩-៣-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥៤០ ផ្លូវជាតិលេខ ៥ ក្រុមទី ១០ ភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មទឹកកកដើម និង ទឹកកកគ្រាប់ នៅក្នុងទីតាំងផ្លូវជាតិលេខ ២ ភូមិក្រាំងស្វាយ ឃុំព្រែកកំពឹស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣- ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៤៧/៩៥ ពម.ប្រ.ក

ស្ដីពីការផ្លាស់ប្ដូរកន្លែង

ធ្វើការរបស់មន្ត្រីរាជការ

* * *

- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងការយល់ព្រមអោយផ្លាស់ ចុះថ្ងៃទី ១៧ និង ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៥ របស់អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា
- ពិនិត្យលើសំណើសុំផ្លាស់ប្ដូរកន្លែងធ្វើការរបស់សាមីខ្លួន ។

សម្រេច

ប្រការ ១ : យល់ព្រមអោយមន្ត្រីរាជការ ០២ នាក់ ផ្លាស់ប្តូរកន្លែងធ្វើការ ពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ កម្ពុជា មកបំរើការងារនៅទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន ។

១– **សុខ ម៉ានយ៉ាន**

២– **ប៉ែត ទិន**

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ដូចប្រការ១ ត្រូវបានទទួលនៅទីស្តីការ ចាប់ពីថ្ងៃទី ០១ - ៨ - ៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងសាមីខ្លួន មានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស : លេខ ១៤៨/៩៥ ពម.ប្រ.ក

ស្តីពីការអនុញ្ញាតអោយសារពត៌មាន «តាសោម» ដំណើរការឡើងវិញ និង ប្តូរឈ្មោះមកជាសារពត៌មាន «សាធារណរដ្ឋ»

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានប្បញ្ញត្តិ មាត្រាទី ១៣៩

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ។

– បានឃើញច្បាប់សារពត៌មាន ដែលសភានៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី១ ។

– បានឃើញលិខិតស្នើសុំរបស់លោក **ខៃ គឹមឆន** ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ១៩៩៥ ។

សំរេច

ប្រការទី១ : អនុញ្ញាតអោយសារពត៌មាន «តាសោម» ដំណើរការឡើងវិញ និងប្តូរឈ្មោះមកជាសារពត៌មាន «សាធារណរដ្ឋ» វិញដោយមានលោក **គោរ សុផល** ជាចាងហ្វាងការផ្សាយ ។

ប្រការទី២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការទី៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការទី៤ : លោក **គោរ សុផល** ចាងហ្វាងការផ្សាយសារពត៌មាន «សាធារណរដ្ឋ» និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការទី៥ : ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២៥ ប្រក.វវស.ប្ម

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះលេខ : ១៨៣ ស.វ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តព្រៃវែង ។
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

សំរេច

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែងចំនួន ២ « ពីរ » នាក់ ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខណ្ឌមន្ត្រី រាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៥ ដោយបោះបង់ចោលការងារ ÷

១ – អ្នកស្រី **ស៊ិន សយ** បុគ្គលិកការិយាល័យសិល្បៈ

២ –លោក **ស៊ិន សំអាន** បុគ្គលិកការិយាល័យវប្បធម៌ស្រុកព្រះស្តេច

មាត្រា ២ : នាយកដ្ឋានបុគ្គលិក និង កិច្ចការសង្គម នាយកដ្ឋានផែនការគណៈនេយ្យនិងហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង ព្រមទាំងសាម៉ីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និង ត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណារ៉ា

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២៦ ប្រក.វវស.ប

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមរបាយការណ៍សាកលវិទ្យាល័យ ហារ៉ៃ ស្តីពីការបោះបង់ចោលការរៀនសូត្ររបស់និស្សិតឈ្មោះ **អ៊ុយ ពិសិដ្ឋ**

សំរេច

មាត្រា ១ : ត្រូវបានលុបឈ្មោះ **អ៊ុយ ពិសិដ្ឋ** បុគ្គលិកសាលាកវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចេញពីបញ្ជីក្របខ័ណ្ឌបុគ្គលិកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ដោយបោះបង់ចោលការងារ ។

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស និង សាលាកវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

នុត ណារ៉ុង

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២៩ ប្រក.ទវស.បុ

ស្តីពីការផ្ទេរក្របខ័ណ្ឌ មន្ត្រីរាជការ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ៧០៦-៩៥ ពម ចុះថ្ងៃទី ២៩-៦-៩៥ របស់ក្រសួងពត៌មាន ស្តីពីការយល់ព្រមទទួលអ្នកស្រី **មាស ម៉ូលី** ។

សម្រេច

មាត្រា ១ : អ្នកស្រី **មាស ម៉ូលី** អនុប្រធានមន្ទីរក្រសួងត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារ នៅក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : ក្រសួងនឹងផ្ទេរប្រាក់បៀវត្សនិងរបបឧបត្ថម្ភផ្សេងៗ របស់អ្នកស្រី **មាស ម៉ូលី** និងក្របខ័ណ្ឌមួយកន្លែងជូនក្រសួងពាណិជ្ជកម្ម ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស និង អ្នកស្រី **មាស ម៉ូលី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និង ត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណារ៉ា

* * *

៥-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៤៩ សក.ដជ.តពយ

ស្ដីពីយានយន្តដែលខូចប្រើប្រាស់លែងកើត

* * *

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នឹងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤-៨៣ លេខ

នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ២៤-១០-៩៤ និង ថ្ងៃទី ៣១-១០-៩៤ ស្តីពីការកែសម្រួលសមាស ភាពរាជរដ្ឋាភិបាលកម្ពុជា ។

- យោងតាមប្រកាសរួមលេខ ១៥០ ប្រក ចុះថ្ងៃទី ០១-៩-៩៤ ស្តីពីការធានារ៉ាប់រងផ្នែករដ្ឋប្បវេណីរបស់ម្ចាស់យានយន្ត ។
- យោងតាមការចាំបាច់របស់អគ្គនាយកដ្ឋានដឹកជញ្ជូន ។

សម្រេច

ប្រការ ១ : ម្ចាស់យានយន្ត និងអង្គភាពរដ្ឋ ឬ អង្គភាពសេដ្ឋកិច្ចចំរុះរដ្ឋ ដែលមានយានយន្តខូចប្រើការលែងកើតទុកចោលដោយសារភាពចាស់ទ្រុឌទ្រោម ឬ ដោយសារគ្រោះថ្នាក់ផ្សេងៗ មិនអាចជួសជុលបាន ឬ ម្ចាស់យានយន្តដែលមានបំណងកំទេចបំផ្លាញយានយន្តរបស់ខ្លួនចោលដោយមូលហេតុផ្សេង ៗ ឬ ត្រូវលក់ទៅប្រទេសទីពីរ ត្រូវធ្វើសេចក្តីរាយការណ៍ អំពីយានយន្តដែលបានបោះបង់ចោល ឬ បានបំផ្លាញចោល ឬ លក់ទៅប្រទេសក្រៅ នេះមក :

ក-អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន បើម្ចាស់យានយន្ត មានអាស័យដ្ឋាននៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាល ។

ខ-មន្ទីរសាធារណការខេត្ត-ក្រុង បើម្ចាស់យានយន្តមានអាស័យដ្ឋាននៅតាមបណ្តាខេត្ត-ក្រុង ។

ប្រការ ២ : របាយការណ៍នេះ ត្រូវធ្វើជាលាយលក្ខអក្សរ ដោយមានសេចក្តីបញ្ជាក់របស់ប្រធានភូមិ និង ឃុំ ឬ សង្កាត់ថា «យានយន្តនេះ ពិតជាបានបំផ្លាញចោលមែន» ។ ក្នុងករណីចាំបាច់ ការិយាល័យត្រួតពិនិត្យយានយន្ត នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវចុះទៅដល់កន្លែង ដើម្បីធ្វើកំណត់ហេតុ នៃការពិនិត្យអង្កេត (Procès verbal de Constat) ដើម្បីទុកជាឯកសារ ។

ប្រការ ៣ : ម្ចាស់យានយន្ត ត្រូវប្រគល់មកជូនការិយាល័យត្រួតពិនិត្យយានយន្ត ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង នូវ :

ក-ប័ណ្ណសំគាល់យានយន្តមួយសន្លឹក

ខ-ផ្លាកលេខយានយន្តទាំងមុខ និងក្រោយ

គ-លិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធនិងយានយន្តនេះ «បើសិនជាយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន»

ប្រការ ៤ : ក្នុងករណីមិនអនុវត្តតាមបញ្ញត្តិ ដែលមានចែងក្នុងប្រការខាងលើនេះទេ ម្ចាស់យានយន្តត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៥ : សេចក្តីប្រកាសនេះចូលជាធរមានបញ្ញត្តិ ចាប់ពីពេលចុះហត្ថលេខាតទៅ ។

ប្រការ ៦ : លោកអគ្គនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃប្រកាសនេះ អោយមានប្រសិទ្ធភាព ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និង ត្រា

អ៊ុង គៀត

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៥១ ប្រក.សក.មាច

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការដ្ឋាន

សាងសង់ព្រលានយន្តហោះពោធិចិនតុង

* * *

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣០-១០-៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងកិច្ចសន្យា ចុះថ្ងៃទី ០៥-១១-១៩៩៤ ស្តីពីការងារជួសជុលព្រលានយន្តហោះពោធិចិនតុង

សំរេច

ប្រការ ១ : ចាត់តាំងគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យនូវការសាងសង់ព្រលានយ

យន្តហោះពោធិចិនតុង ដែលមានសមាសភាព ដូចខាងក្រោម :

១–ឯកឧត្តម	**ខឹម គឹមស្រួន**	ប្រធាន
២–តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី		សមាជិក
៣–តំណាង ក្រសួងហិរញ្ញវត្ថុ		សមាជិក
៤–តំណាង អាជ្ញាធរអាកាសចរស៊ីវិល		សមាជិក
៥–លោក	**មាសកេត្ត កែមីរ៉ាន** អគ្គនាយក	សមាជិក
៦–លោកស្រី	**អ៊ឹង ឈាងលី** នាយកការិយាល័យ គណនេយ្យ ហិរញ្ញវត្ថុ-ជំរះបញ្ជី	សមាជិក
៧–លោក	**ខា ស៊ាងហុង**	សមាជិក
៨–លោក	**ផែន សុទីដ្ឋារ៉ា**	លេខាធិការ

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច ដូចខាងក្រោម :

– ត្រូវធ្វើការពិនិត្យ និង ទទួល នូវការដ្ឋានជួសជុលព្រលានយន្តហោះ ពោធិចិនតុង ដែលធ្វើដោយក្រុមហ៊ុន MEADA អោយបានសមស្របតាមខ្លឹមសារ នៃកិច្ចសន្យា ចុះថ្ងៃទី ០៥–១១–៩៤ ។ ត្រូវរៀបចំបែបបទ និង លិខិតស្នាមផ្សេងៗ សំរាប់ការងារ គ្រប់គ្រង និង ប្រើប្រាស់ អចលនៈទ្រព្យអោយបានសមស្របតាមគោលការណ៍ច្បាប់ របស់រដ្ឋ ។

ប្រការ ៣ : លោកអគ្គនាយក លោកនាយកខុទ្ទកាល័យ នាយក នាយកដ្ឋានការងារថ្មី និង ឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាម ខ្លឹមសារ នៃប្រកាសនេះ អោយមានប្រសិទ្ធភាព និង ទទួលបានលទ្ធផលល្អ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន

ហត្ថលេខា និង ត្រា

អ៊ឹង ហ៊ួត

* * *

៦-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៤៤ / ៩៥ កធស.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ

ក្នុងក្របខ័ណ្ឌ ក្រសួងធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើត ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ : ១៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ : ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា
- តាមសេចក្តីស្នើសុំរបស់មន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំងលេខ : ២៣-៩៥ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ១៩៩៥ និង លេខ ២៤-៩៥ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : លោក **សោម សារិន** បុគ្គលិកការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច និង លោក **ញ៉ឹក សុខុម** បុគ្គលិកឧទ្ទកាល័យនៃក្រសួងធម្មការ និង សាសនាត្រូវផ្ទេរ អោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **សោម សារិន** និងលោក **ញ៉ឹក សុខុម** ត្រូវផ្ទេរជូនមន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង និង លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវ អនុវត្តតាមសេចក្តីប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

៧-ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២៥៥ ប្រក.បស្ថ

ស្តីពីការទទួលស្គាល់ និង ប្រគល់ភារកិច្ច

ជូនមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខនស.រកត ១០-៩៤-៨២ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងលិខិតលេខ ២០៨ ប្រ.ក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងមហាផ្ទៃ
- ពិនិត្យលើការចាំបាច់របស់មន្ទីរគ្រប់គ្រងបរិស្ថានខេត្តរតនៈគីរី ។

សំរេច

ប្រការ ១ : ទទួលស្គាល់ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ដូចមានឈ្មោះខាងក្រោម :

១-លោក **ប៉ូ តាន់** អោយបំរើការងារនៅមន្ទីរគ្រប់គ្រងបរិស្ថានខេត្តរតនៈគិរី

២-លោក **សាន សានី** អោយបំរើការងារនៅមន្ទីរគ្រប់គ្រងបរិស្ថានខេត្តរតនៈគិរី

ប្រការ ២ : ប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេង ។ របស់សាមីខ្លួន ក្រសួងគ្រប់គ្រងបរិស្ថានជានាផ្គត់ផ្គង់បន្តបន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ មន្ទីរគ្រប់គ្រងបរិស្ថានខេត្តរតនៈគិរី អង្គភាពដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២៥៦ ប្រក.បស្ថ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តស្វាយរៀង លេខ ២៨ បដ្ឋ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៤ និង ការឯកភាពរបស់អភិបាលខេត្តស្វាយរៀង លេខ ២៩៣កប ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យលើការចាំបាច់របស់មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តស្វាយរៀង ។

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការថ្នាក់ការិយាល័យ ចំណុះអោយមន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តស្វាយរៀង ដូចមានរាយឈ្មោះខាងក្រោម :

- លោក **សោម យ៉ុន** ជាប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និង ហិរញ្ញកិច្ច
- លោក **អ៊ុន ប្រាសាទ** ជាប្រធានការិយាល័យអប់រំបរិដ្ឋាន ការពារធម្មជាតិ និង កិច្ចការច្បាប់
- លោក **ម៉ៅ ឈឿន** ជាប្រធានការិយាល័យផែនការបរិដ្ឋាន និង ត្រួតត្រាការប្រតិបត្តិ
- លោក **ម៉ែន ជា** ជាអនុប្រធានការិយាល័យផែនការបរិដ្ឋាន និង ត្រួតត្រាការប្រតិបត្តិ

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានកែសំរួលតាមតួនាទី ភារកិច្ចថ្មីរបស់ខ្លួន ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយក មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តស្វាយរៀង អង្គភាពដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តំលៃ ៦០២ រៀល